**ប្រការ៤.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាម៉ាស្ទ័រអន្តរជាតិ** ត្រូវមានកម្មវិធីសិក្សាភាសាបរទេសណាមួយជាមុខវិជ្ជាគោល នៃកម្មវិធីសិក្សារបស់ខ្លួន។

**ប្រការ៥.-**

លោកស្រី **ឡូរ៉ាន អេសប្ដារ៉ាស** ជានាយិកាគ្រឹះស្ថានសិក្សាត្រូវដឹកនាំ និងគ្រប់គ្រងសាលារៀន ទាំងផ្នែករដ្ឋបាល និងផ្នែកបច្ចេកទេស ព្រមទាំងទទួលខុសត្រូវះ

- ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យ
- ជ្រើសរើសសិស្សឱ្យចូលរៀនដោយមិនមានការរើសអើង
- ធានាដំណើរការបង្រៀន និងរៀនឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាព
- គោរព និងអនុវត្តសារាចរ សេចក្ដីណែនាំ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ធានាសណ្ដាប់ធ្នាប់សង្គម និងធានាសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តចំពោះសិស្សគ្រប់រូប
- ធ្វើរបាយការណ៍រាល់សកម្មភាពសិក្សាផ្នែករដ្ឋបាល និងបច្ចេកទេស ជូនមន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ និងក្រសួងអប់រំ យុវជន និងកីឡាតាមការកំណត់។

**ប្រការ៦.-**

ក្រសួងអប់រំ យុវជន និងកីឡាមានសិទ្ធិធ្វើអធិការកិច្ច ត្រួតពិនិត្យតាមដាន និងវាយតម្លៃ ហើយមានសិទ្ធិបិទ ប្រសិនបើគ្រឹះស្ថានសិក្សានេះអនុវត្តខុសពីកិច្ចសន្យាដែលបានចុះជាមួយក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៧.-**

គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាម៉ាស្ទ័រអន្តរជាតិ** ត្រូវបានកំណត់ឱ្យមានសុពលភាពរយៈពេល៥ឆ្នាំដោយគិតពីឆ្នាំ ២០១៥ ដល់ឆ្នាំ ២០២០ ពេលផុតកំណត់គ្រឹះស្ថានសិក្សាត្រូវសុំបន្តសុពលភាពសារជាថ្មី។

**ប្រការ៨.-**

អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ អគ្គាធិការដ្ឋាន នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានអប់រំកុមារតូច នាយកដ្ឋានបឋមសិក្សា អង្គភាពពាក់ព័ន្ធ នៃក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តបន្ទាយមានជ័យ និងគ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន **សាលាម៉ាស្ទ័រអន្តរជាតិ** និងសាមីជនមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ២០១៥

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**កន្លែងទទួល**

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងមុខងារសាធារណៈ

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-សាលាខេត្តបន្ទាយមានជ័យ

*"ដើម្បីជូនជ្រាបជាព័ត៌មាន"*

-ដូចប្រការ៨

*"ដើម្បីអនុវត្ត"*

-កាលប្បវត្តិ- ឯកសារច្រកចេញចូលតែមួយក្រសួងអប់រំ យុវជន និងកីឡា

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ៤២៧ ៣៨៦ / ៤២៦ ៩៥១ / ២១២ ៥១២
E-mail: crsmeys@camnet.com.kh / yangyano@camnet.com.kh Web Site: www.moeys.gov.kh